Free
សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១១ដុល្លារ
- ធានា លើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

## ព័ត៌មានសំខាន់ៗខាងក្នុង...

**ក្រុមកីឡាបាល់ទាត់យុវជនឡូវែល**

*សូមអាននៅទំព័រទី ០៣*



**សាលមហោស្រព MCC ទើបសម្ពោសន៍នៅកណ្ដាលក្រុងឡូវែល**

*សូមអាននៅទំព័រទី ០៤*



**ការទទួលជំនាញ និងការងារថ្មីៗរបស់ជនអន្តោប្រវេសន៍...**

*សូមអាននៅទំព័រទី ០៨*




**Lowell Community Health Center AWARDED**

*Please Read Page 09*



# ឡូវែលបោះឆ្នោតផ្តាច់ព្រ័ត ថ្ងៃទី៦ វិច្ឆិកា ២០១៨




ឡូរី ត្រាហាន ទើបនឹងប្រកាសឈ្នះឆ្នោតជុំទី១

ដោយ ពិន សំខុន

បេក្ខនារី"ឡូរី ត្រាហាន"ទើបនឹងប្រកាសថា ឈ្នះ លើបេក្ខជន"ដាន់ កូហ៏"ដែលបានទទួលព្រមថាចាញ់ កាលពីថ្ងៃទី១៧កញ្ញាមុននេះ ដោយការរាប់សន្លឹកឆ្នោតច្រើនជងនៅតំបន់"ឡូវែល"នឹង "ឡូវិន", ជាពិសេសបេក្ខជន"ដាន់ កូហ៏"តវ៉ាថា

---

"នយោបាយកម្ពុជា"

# នៅពេល ហ៊ុន សែន មកអង្គការសហប្រជាជាតិ

ដោយ ពិន សំខុន

លោកនាយករដ្ឋមន្ត្រីខ្មែរ នឹងមកដល់ទីក្រុងញូយ៉ក ចូលរួមប្រជុំសន្និបាទប្រចាំឆ្នាំនៃអង្គការសហប្រជាជាតិនៅថ្ងៃ២៨-២៩កញ្ញានេះ ក្នុងពេលដែលស្ថានភាពកម្ពុជាកំពុងប្រឈមមុខនឹងការដាក់ទណ្ឌកម្មរបស់ប្រទេសលោកសេរីផង នឹងការព្យួរអាសនៈកម្ពុជាពីអ.ស.ប.ផង ដោយសារកម្ពុជាបានប្តូរចរន្តនយោបាយ ពីការអនុវត្តន៏"លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស" ទៅរក"របបលទ្ធិផ្តេចការ



និយមឯកបក្សគ្រួសារនិយម" ។ លោក ហ៊ុន សែន នឹងឡើងធ្វើសេចក្ដីថ្លែងការនៅវេទិការអ.ស.ប. ថ្ងៃទី២៩កញ្ញា នៅពេលដែលសហគមន៏ខ្មែរនៅក្រៅប្រទេសច្រើនក្រុមៈ ខ្លះខាងសមាជិកគាំទ្រគណបក្សប្រជាជន(ចំនួនតិចតួច)ត្រៀមខ្លួនទទួលមកស្វាគមន៏, ខ្លះទៀតខាងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិត្រៀមធ្វើបាតុកម្មប្រឆាំងនឹងវត្តមានលោក ហ៊ុន សែន តែជាពីក្រុមបែកគ្នា (មានចំនួន

តទៅទំព័រទី២

មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ





978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com



ឱសថស្ថាន សេនធូរី
CENTURY PHARMACY
ផ្តល់នូវសេវាកម្មពិសេស និងផ្តោតលើតំរូវការរបស់អតិថិជនម្នាក់ៗ
ថ្នាំផ្សំមានប្រសិទ្ធភាពស្របតាមវេជ្ជបញ្ជា
វិចខ្ចប់ដោយប្លាស្ទិក
ដឹកជញ្ជូនដោយឥតគិតថ្លៃក្នុងឡូវែល, ឆែមហ្វឺត, ទឹងប្ឃ្ស៍, តេសប៊ូរី, ដ្រាចេត, ឡូវិន
ងាយស្រួលក្នុងការផ្ទេរវេជ្ជបញ្ជាពីឱសថស្ថានមួយទៅឱសថស្ថានផ្សេងទៀត
មានជំនួយការខាងឱសថជនជាតិខ្មែរ
www.centuryrx.net
937 Gorham Street • Lowell, MA 01852
978-455-6554 • Fax: 978-455-9476

តមកពីទំព័រទី ០១

# នៅពេលដែល ហ៊ុន សែន មកអង្គការ...

ច្រើន ពួកគេជាអតីតជនភៀសខ្លួន) -ក្រុមចរន្ត គាំទ្រលោក សម រង្សី សង្គ្រោះជាតិអាមេរិកាប្រកាសធ្វើបាតុកម្មថ្ងៃទី២៨នឹងក្រុមចរន្តសង្គ្រោះជាតិដើមធ្វើបាតុកម្មនៅថ្ងៃទី២៩ នៅទីក្រុងញូយ៉ក




នាវិមានអ.ស.ប.ដូចគ្នា។

ដើម្បីទប់ទល់នឹងការប្រុងនឹងដាក់ទណ្ឌកម្មទាំងនោះ ប្រទេសកម្ពុជាទើបនឹងធ្វើការបោះឆ្នោតចប់រួចរាល់ កាលពីខែមុន ហើយ"គណបក្សប្រជាជនកម្ពុជា"ក៏បានដណ្តើមយកអំណាចសភាជាតិទាំងអស់ មាន១២៥អាសនៈ ដោយការរំលាយគណបក្សសង្គ្រោះជាតិដែលជាគណបក្សប្រឆាំងដ៏ធំបំផុតមួយ នឹងដាក់សមាជិកគណបក្សតូចតាចចំនួន១០ ដែលបានមកប្រជែងនឹងខ្លួន ក្នុងរូបភាពជាពហុបក្សតែមិនបានអាសនៈសូម្បីតែ១នោះ ឱ្យមកចូលរួមជាទីប្រឹក្សា។ រដ្ឋាភិបាលរបស់គណបក្សប្រជាជនថ្មីនេះ មានសមាជិកច្រើនរយនាក់ ដោយមានរាប់បញ្ចូលទាំងមន្ត្រីមកពីគណបក្សតូចតាចក្នុងឋានៈជាទេសរដ្ឋមន្ត្រី"៣០រូប" ដែលមិនបានជាប់ឆ្នោតឱ្យចូលជាសមាជិករដ្ឋាភិបាលថ្មីនោះផងដែរ។

នៅពេលដែលសហរដ្ឋអាមេរិកប្រារព្ធនយោបាយដកខ្លួនថយពីអាស៊ី កម្ពុជាសព្វថ្ងៃក៏ទៅនៅក្រោមអនាព្យាបាលរបស់ចិនប្រជាមានិត ដែលធ្វើឱ្យប្រជាពលរដ្ឋកំពុងតែថ្ងូរ នឹងព្រួយបារម្ភថា "ប្រទេសចិនកំពុងបញ្ជូនពលរដ្ឋចិនឱ្យមកដណ្តើមទឹកដីនឹងជីវភាពរបស់ខ្មែរយ៉ាងរន្ធើនគួរឱ្យខ្លាច, នៅពេលដែលប្រទេសយួនក៏នៅតែជាការគម្រាមកំហែងដល់ពលរដ្ឋខ្មែរនៅឡើយ"។ ប្រទេសចិនដើម្បីទប់ទល់នឹងកម្លាំងលោកសេរី បានចងសម្ព័ន្ធមិត្រជាមួយប្រទេសរុស្ស៊ី ដែលជាមហាអំណាចកុម្មុយនិស្តដ៏ធំមួយទៀត ធ្លាប់មានមហិច្ឆិតាត្រួតត្រាពិភពលោកដែរ ដើម្បីពង្រីងជំហរយោធារបស់ខ្លួន នៅមុំមហាសមុទ្រចិន នឹងកន្លែងជាច្រើនទៀតនៅជុំវិញប្រទេសឥណ្ឌា...។

សហរដ្ឋអាមេរិក ថ្វីត្បិតតែនៅឆ្ងាយពីសហភាពអឺរ៉ុប តែទាំង២នាក់បានមើលឃើញថាប្រទេស"ចិនមានមហិច្ឆិតាឈោមត្រជាក់ តែលាក់គំនួចឆ្វេតប្រវិញ្ញយកប្រទេសទន់ខ្សោយដោយគ្មានចម្បាំងរាំងជល់គ្មានកិច្ចសន្យា គ្មានកិច្ចព្រមព្រៀងឱ្យតែអ្នកឯងត្រូវការឱ្យចិនជួយ អ្នកឯងនឹងត្រូវចេញថ្លៃខាតបង់យ៉ាងពេញទំហឹងជាមិនខាន។

កម្ពុជាបានស្គាល់ចិនជាមិត្រទី១ តាំងតែពីសម្តេចស៊ីហនុជាព្រះប្រមុខរដ្ឋនាអម្លុងឆ្នាំ១៩៦០ តែខ្មែរពេលនេះទុកចិត្តមហាមិត្ររហូតដល់គេលូកថ្លើមក៏មិនអីដែរ, មែន! ចិនមិនបានអត់អោនឱ្យមិត្រទី១របស់ខ្លួននោះទេ មកជួយជួសជុលកំពុងផែសមុទ្រ ក្រុងព្រះសីហនុក៏ក្លាយទៅជា"ទីក្រុងចិន", មកសង់រោងចក្រឱ្យកម្មករ ក្រុងភ្នំពេញក៏ក្លាយជាវិនិយោគរបស់ចិនទាំងមូល, មកជួសជុលប្រាសាទបូរាណខ្មែរ សៀមរាបក៏ក្លាយទៅជាក្រុងទេសចររបស់ចិន, ...ប្រជាពលរដ្ឋខ្មែរនៅសល់តែភ្នែកសម្រាប់"យំ"តែប៉ុណ្ណោះ... នេះហើយដែលតំណាងរាស្ត្រខ្មែរពអាណត្តិ នៅក្រុងឡូវែលដ៏ឆ្លាតវៃ "រ៉ាឌីម៉ម មិនព្រមឈប់ពីការសសើរសំណាងខ្លួន ពីព្រោះតែបានទទួលស្វាគមន៏លោក ហ៊ុន សែន រាជរដ្ឋាភិបាលខ្មែរដំណាងឱ្យចិននៅលើទឹកដីសេរីភាពសហរដ្ឋអាមេរិក នៅពេលដែលខ្មែរអាមេរិកាំង ទៅពីឡូវែលដ៏ច្រើនគ្នាខឹងសម្បារយ៉ាងខ្លាំងចំពោះបុគ្គលម្នាក់នោះ។

លោក ហ៊ុន សែន នឹងមកកាពារអាសនៈរដ្ឋាភិបាលកម្ពុជានៅអ.ស.ប. ជាមួយនឹងអ្វីដែលលោកបានត្រៀមបង្ហាញពីរដ្ឋាភិបាល"ផ្តាច់ការស្របច្បាប់"របស់លោក បង្ហាញពីសម្ព័ន្ធមិត្រជា"ថៅកែនឹងជាខ្នងបង្អែកបរទេស"របស់លោក។ លោកក៏នឹងបានសប្បាយចិត្តខ្លះដែរ ដោយនៅខាងក្រៅបរិវេណឯណោះអ្នកប្រឆាំងរបស់លោក គឺគណបក្សសង្គ្រោះជាតិបានបែកគ្នាជា២ជម្រៀក ដោយលោកសម រង្សី មិនព្រមនៅជាសង្គ្រោះជាតិគំរូដើម មិនព្រមទទួលស្គាល់ថា កូនស្រីរបស់លោក កឹម សុខាក៏ធ្វើការបានប្រសើរសម្រាប់សង្គ្រោះជាតិផងដែរនោះទេ ម្លោះហើយក៏វាយប្រហារ ហ៊ុន សែន បានបែបខ្សោយៗ។

តាមពិតទៅគណបក្សសង្គ្រោះជាតិមិនបានរលាយ ដូចដែលលោក ហ៊ុន សែន បានប៉ងប្រាថ្នានោះទេ, ពលរដ្ឋដែលបានស្រឡាញ់នឹងការពារលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ជាងពាក់កណ្តាលនគរនៅតែទទូចចង់បានលទ្ធិនោះជូនប្រទេសរបស់ខ្លួនតែដដែល បើទោះជាមានការប៉ុនប៉ងបំបែកគណបក្សនោះជាជំរៀកក៏ដោយ ឬក៏ប៉ុនប៉ងថា "កឹម សុខា មិនមានលទ្ធភាពតស៊ូពីក្នុងគុកក៏ដោយ", តើ ហ៊ុន សែន នៅបន្តរទប់ទល់ចរន្តតស៊ូរបស់ពល



លោក សម រង្ស៊ី

រដ្ឋខ្មែរ ដែលនៅជាមួយនឹងសហប្រជាជាតិនោះ បានយូរប៉ុណ្ណា? ប្រជាពលរដ្ឋសម័យនេះ អាចមើលឃើញ"មិត្រ"នឹង"សត្រូវ"បានដោយសារបច្ចេកវិជ្ជាទំនើប នឹងដោយស្មារតីចង់បានសេរីភាពដូច្នេះ លទ្ធិប្រជាធិបតេយ្យក៏នឹងរីកធំធេងជាលំដាប់ជាមួយ"ពលរដ្ឋខ្មែរជាមិត្រ"បានមិនមែនរស់នៅជាមួយជនផ្តាច់ការនោះទេ។

ដំណើរមកញូយ៉ករបស់លោក ហ៊ុន សែន គឺជាឆាកល្ខោនថ្មីមួយទៀត ដែលរៀបចំយ៉ាងល្អិតល្អន់ ដើម្បីការពាររបប"ផ្តាច់ការ"ដែល ហ៊ុន សែន នឹងក្រុមគ្រួសារគាត់ ឱ្យត្រូវនៅជាអ្នកគ្រប់



លោក កឹម សុខា

គ្រងបន្តរទៅទៀតតែប៉ុណ្ណោះ, ពួកបរទេសខ្លះ អាចមិនយល់ច្បាស់ពីការបន្លំភ្នែករបស់ក្រុមល្ខោនមួយនោះ ពីព្រោះមានក្រុមខ្មែរខ្លះ ដែលមានភាគផលចំណេញខំប្រឹងសំដែងខ្លាំងណាស់ដែរ។



# ក្រុមកីឡាបាល់ទាត់យុវជនឡូវែល
# Massachusetts Youth Soccer

ដោយខ្មែរផុសស.រ.អា.

យុវៈកីឡាករនៅឡូវែលប្រមាណ៩០០នាក់ មានកុមារា-កុមារី-បានយុវជន-យុវនារី បានមកហាត់ហ្វឹកហ្វឺន ជាទៀងទាត់រាល់ថ្ងៃសៅរ៍ ចាប់ពីម៉ោង៨ព្រឹកទៅ រហូតដល់ពេលរសៀល ។ នាថ្ងៃសៅរ៍នោះ កីឡាករទាំងអស់ ត្រូវស្លៀកឯកសណ្ឋានជាសំគាល់ក្រុមរបស់ខ្លួន ដើម្បីចូលប្រគួតនឹងក្រុមដ៏ទៃឯទៀត ឱ្យដូចគ្នាជាក្រុមវិជ្ជាជីវៈដែរ... គឺជាភាពអស្ចារ្យ ដែលកុមារទាំងឡាយចូលប្រគួតគ្នាពេញមួយម៉ោងដោយមានគ្រូបង្ហាត់ នឹងអាជ្ញាកណ្តាលសម្រាប់គ្រប់ ប្រគួតផង។ មានតែថ្ងៃហាត់ដែលគ្មានការប្រគួតទេ ដែលកីឡាករអាចប្រើសម្លៀកបំពាក់សេរីបាន។

ព្រឹកថ្ងៃសៅរ៍ទី២២នេះ ប៉ុណ្ណារ៉ូ ក្នុងក្រុមកីឡាករ៨នាក់មានស្រីពនាក់ អាយុ៨-៩ឆ្នាំ ពាក់ឯកសណ្ឋានសញ្ញា"ឆ្កែចចក"អាវពណ៌ប្រផេះ ខោខ្មៅ ស្រោមជើងខ្មៅ ស្បែកជើងមានក្រចាប់ដូចក្រុមមនុស្សធំដែរ ត្រូវជួបប្រគួតជាមួយក្រុមត្រី "ភីរ៉ាណា" ដែលមានសម្លៀកបំពាក់ដូចគ្នា ខុសត្រង់អាវពណ៌ឈាមជ្រូកតែប៉ុណ្ណោះ -ក្រុម "ភីរ៉ាណា"ក៏ជាក្រុមកីឡាករ មានស្រីមានប្រុសក្នុងអាយុ៨-៩ឆ្នាំដូចគ្នា។ ពឆ្នាំហើយដែល ប៉ុណ្ណារ៉ូ ចុះឈ្មោះរៀនបាល់ទាល់មណ្ឌល"Lowell Youth Soccer"នោះ ឆ្នាំនេះគេផ្តោតអារម្មណ៍លើកីឡាបានច្រើនជាងប្រឡែងលេងជាមួយមិត្រឯទៀត១ មិនតែប៉ុណ្ណោះ គេបានយល់តួរនាទីរបស់គេច្បាស់លាស់ ក្នុងសៃវៀនប្រគួតទៀតផង។ កាលពីសប្តាហ៍មុន គ្រាន់តែ ប៉ុណ្ណារ៉ូ ច្រឡំពាក់ស្បែកជើងលេង


ក្រុមកីឡា"ឆ្កែចចក"


រីតនី អ៊ីលីយ៉ុត ប្រធានក្រុមយុវកីឡាបាល់ទាត់នៅឡូវែល



ក្រុមកីឡា"ឆ្កែចចក" ប្រកួតនឹងក្រុម "ភីរ៉ាណា"

"បេសបូល"មកចូលប្រគួត"សកកឺរ"បានត្រូវអាជ្ញាកណ្តាលត្រួតពិនិត្យឃើញ គេមិនអនុញ្ញាតឱ្យចូលប្រកួតបានទេក៏ខានលេងអស់១ម៉ោងគឺ១ថ្ងៃទទេទៅ។ ថ្ងៃនេះ ឯកសណ្ឋាណស្លៀកត្រូវគ្រប់គ្រាន់ហើយ បែរជាទៅទាត់បាល់ចាញ់ក្រុម"ពីរ៉ាណា"ដល់ទី៣គ្រាប់ គឺ៤ទល់នឹង៧គ្រាប់ គួរឱ្យស្តាយណាស់ ក្រុមអ្នកមើលភាគច្រើនជាម្តាយឪពុកអ្នកកីឡាករ មានមកលើកទឹកចិត្ត ក៏មានច្រើនផងដែរ។

ទិដ្ឋភាពនៃទីលានប្រគួត"Edward Soccer Complex" នៅរៀងរាល់ថ្ងៃសៅរ៍ ជាពិសេសថ្ងៃសៅរ៍ ទី២២នេះ មេឃក៏ផ្តើមត្រជាក់បន្តិចមែនក្តី តែមេឃស្រឡះល្អណាស់ ដីនៅសើមបន្តិចៗធ្វើឱ្យស្មៅមានភាពស្រស់បស់ តែក្រុមប្រគួតពេលជាមួយគ្នាមានប្រមាណជា១០ក្រុម ហាក់ដូចជាក្រឡាចត្រង្គ ចម្រុះពណ៌រត់ប្រសេចប្រសាច ដោយពណ៌អាវជាក្រុមខុសៗគ្នា គួរឱ្យចង់ទស្សនាណាស់ ។ គ្រួសារខ្មែរជាច្រើន បាននាំកូនទៅចុះឈ្មោះចូលហាត់កាន់តែច្រើនជាងឆ្នាំមុនៗ ខ្លះក៏ឃើញពូកែលេងខ្លាំងណាស់ គួរតែជាសេចក្តីសង្ឃឹមសម្រាប់អនាគតទាំងផ្នែកសុខភាព ផ្នែកកីឡា ក៏ដូចជាផ្នែកសិក្សារបស់កូនដូច្នោះដែរ។

លោក រីតនីយ អេលីយ៉ុត បច្ចុប្បន្នជាសមាជិកក្រុមប្រក្សាជាប្រធាននៃចលនា"កីឡាបាត់ទាត់នៅឡូវែល"តាំងតែពីច្រើនឆ្នាំណាស់ហើយ តែងតែញញឹមជានិច្ចទទួលភ្ញៀវតាំងពីព្រលឹមស្រាង នៅកន្លែងលក់"Snacks"នឹងភេសជ្ជៈ ជូនគ្រួសារកុមារនឹងយុវៈកីឡាករ លោកជួយគេឯងគ្រប់គ្នា ដែលមិនមែនជាការងាររបស់លោក ពីព្រោះតែកិច្ចការជាភារកិច្ចរបស់លោក បានដើរតតខ្មោះរួចទៅហើយ បើទោះជាមិនមានលោកក៏ដោយ។

# ទឹកមានអត្ថប្រយោជន៍អ្វីខ្លះចំពោះសុខភាព



អ្នកអាចបន្ថែមសំណើមដល់ស្បែកធ្វើឱ្យស្បែកមុខ និងស្បែកសព្វ រាងកាយទន់រលោងស្អាត ដោយការទំលាប់ ទទួលទានទឹកឱ្យច្រើនៗ ក្នុងមួយថ្ងៃៗ។ បរិមាណទឹកដែលអ្នកត្រូវទទួលទាន គឺឱ្យបាន ៨ ទៅ ១០ កែវ ប៉ុន្តែដើម្បីទទួលទាន ឱ្យបាននៅក្នុងបរិមាណនេះ អ្នកត្រូវដឹងថា ត្រូវទទួលទានបែបណា? មិនមែនឱ្យអ្នកទទួលទានតែ១ដង ឱ្យគ្រប់បរិមាណខាងលើនេះទេ គឺអ្នកត្រូវបែងចែកការទទួលទាន ឱ្យបានខ្ជាប់ខ្ជួន ពេញមួយថ្ងៃ ឬអាចទទួលទានតាមការណែនាំដូចខាងក្រោមៈ

-ពេលភ្ញាក់ពីគេងទទួលទានទឹក ១ ឬ ២កែវ។

-មុនពេលអាហារព្រឹកទទួលទានទឹក ១កែវកន្លះ។

-ពេលអាហារព្រឹកដល់ថ្ងៃត្រង់ ទទួលទានទឹក១កែវ។

-ក្រោយអាហារថ្ងៃត្រង់ ទទួលទានទឹក ១កែវកន្លះ។

-ពេលរសៀល ដល់ល្ងាច ទទួលទានទឹក ១កែវ។

-ក្រោយពេលអាហារល្ងាច ទទួលទានទឹក ១ កែវកន្លះ។

-មុនពេលចូលគេងទទួលទានទឹក១កែវ។

ប្រសិនបើអ្នកបែងចែកការទទួលទានទឹក ដូចខាងលើនេះ ខ្ជាប់ខ្ជួន នឹងធ្វើឱ្យរាងកាយរបស់អ្នកបានទទួល បរិមាណទឹកគ្រប់គ្រាន់ ហើយក្រៅពីនេះ អ្នកអាចបន្ថែមការទទួលទានទឹកផ្លែឈើ ផ្សេងៗតាមចំណង់ចំនូលចិត្តរបស់អ្នក។

បរិមាណទឹកស្អាត ដែលអ្នកទទួលទានបានគ្រប់គ្រាន់ សម្រាប់តម្រូវការ របស់រាងកាយ និងជួយសំអាតរាងកាយ ផ្តល់សំណើមដល់ស្បែកឱ្យរលោងភ្លឺថ្លា។ ប្រសិនបើអាកាសធាតុក្តៅ គួរប្រើវិធីទទួលទាន ទឹកម្តងបន្តិចៗ តែញឹកញយដងបាន។

# សាលមហោស្រព MCC ទើបសម្ពោធន៏នៅកណ្តាលក្រុងឡូវែល

ដោយខ្មែរផុសស.រ.អា

សាលមហោស្រពថ្មី ស្រឡាងមួយរបស់មហាវិទ្យាល័យសហគមន៏"មីឌូលសិច"MCC ដែលមានឈ្មោះថា"Richard &Nancy Donahue Family Academic Art Center"បានត្រូវសម្ពោធន៏នឹងកាត់ខ្សែរបូរយ៉ាងឱឡារិក កាលពីរសៀលថ្ងៃសុក្រទី២០កន្លងទៅនៅ២៤០ផ្លូវ Central St. Lowell ដោយមានមន្ត្រីអ្នកមុខអ្នកការជាច្រើន ប្រមាណជាពាវយនាក់ ចូលរួមជាកិត្តិយសផង។

ស្ថិតនៅចំកាច់ជ្រុងផ្លូវ"មីដូលសិច"នឹងផ្លូវ"សង់ត្រល"នាកណ្តាលក្រុងឡូវែល អាគារដ៏ចំណាស់រយឆ្នាំមួយ បានប្រែរូបជាអាគារទំនើបមួយ មានតួនាទីជាកេរ៏តែសំខាន់ទៅទៀត សម្រាប់បន្តកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រខាងផ្នែកសិល្បៈរបាំ-ដូរ្យតន្ត្រីនៅឡូវែល ហើយបើកឱ្យប្រើជាផ្លូវការ នាថ្ងៃចុងបញ្ចប់នៃរដូវក្តៅ២០១៨ នៅសហរដ្ឋ ដោយ

លោកប្រធានសាលា MCC បណ្ឌិត ជេម ម៉ាប្រី នេះទៅហើយ។

ឈ្មោះគ្រួសារ"ដណាហ៊ូ" នឹងជាឈ្មោះរបស់"រីកឆើត"ជាមេធាវីដ៏ល្បីល្បាញ ដែលបានធ្វើជាឧបការីរបស់ប្រធានាធិបតី ជន ខេណ្ណឺឌី ដែលបានបានបង់ជីវិតនៅឆ្នាំ២០១៥ តែ"ណាន់ស៊ី"នៅបន្តកាន់ទង់អភិវឌ្ឍន៏វប្បធម៌ បន្តពីប្តីរបស់លោកស្រីរហូតដល់បានសម្ទិទ្ធិត្រចះត្រចង់ចុងក្រោយបង្អស់នេះ ទុកឱ្យកុលបុត្រកុលធីតាក្រុងឡូវែលម្តង



Middlesex Community College President James C. Mabry was joined by local officials, community leaders, and MCC faculty and staff to cut the ribbon to officially open the newly renovated Richard & Nancy Donahue Family Academic Arts Center on the Lowell campus.



Philanthropist Nancy Donahue addressed the nearly 200 guests gathered to celebrate the opening of MCC's newly renovated Richard & Nancy Donahue Family Academic Arts Center on the Lowell campus.



នាយកសាលាក្រុងឡូវែលផងនោះ គឺជាកេរឈ្មោះនៃគ្រួសារ ដែលបានរក្សាប្រវត្តិដ៏រុងរឿងនៃសិល្បៈរបាំនឹងដូរតន្ត្រីនៅឡូវែល តាំងពី១៥០ឆ្នាំមកហើយ, ជាថ្មីម្តងទៀត"ណាន់ស៊ី ដណាហ៊ូ"ជាភរិយា

តទៅទំព័រទី ១៥




ទិដ្ឋភាពខាងក្រៅសាលមហោស្រពថ្មី



# វេជ្ជបណ្ឌិត សុខារិទ្ធិ ម៉ី
## DR. SOKHARITH MEY, MD



## ចាប់ផ្តើមទទួលអ្នកជំងឺថ្មី
## ទាំងពីរការិយាល័យឡូវែល & លីន

**Now Accepting New Patients at both Offices**

**Family Medicine & Behavioral Health**

**Please Call Us To Enroll:**

**Lowell - (978) 455-7992**

**Lynn - (781) 780-7755**

ផ្នែកជំងឺទូទៅ និងជំងឺផ្លូវចិត្ត

មណ្ឌលពិនិត្យសុខភាពឡូវែល
**Lowell Primary Care Center**
1075 Westford St. Unit 204
Lowell, MA 01851

មណ្ឌលពិនិត្យសុខភាពលីន
**Lynn Primary Care Center**
280 Union St. Unit 402
Lynn, MA 01901

បុគ្គលិកនិយាយភាសាខ្មែរ/ Staff speak Khmer
We accept MassHealth, Medicare and other health insurances

"ទស្សនៈមាននឹងក្រ"

# គួរយល់ដឹងពីប្រាក់ចំណូលក្នុងផ្ទះដែរឬទេ?

ដោយ ពិន សំខុន

ប្រាក់ចំណូលក្នុងផ្ទះយើងមានរៀងរាល់ថ្ងៃ ចំនួនដដែលៗ មិនឡើងមិនចុះ តែយើងទិញរបស់ប្រើប្រាស់ក្នុងគ្រួសារបានតិចទៅៗ ពេលខ្លះត្រូវ "ចំណាយចាំបាច់ធំ"តែម្តង ក៏វ៉ាន់កខ្វល់ខ្វាយនឹងសេចក្តី"ក្រ"ទប់ទល់ជីវភាពលែងជាប់ ។ រីឯនៅផ្ទះមួយទៀត ជាប់របងយើង បែបជាកូនចៅចិនបន្តិចផង មានស្ថានភាពសេដ្ឋកិច្ចដូចគ្នា ប្រាក់ចំណូលប្រហែលគ្នា តែគេបែរជាហាក់ដូចជាចម្រុងចម្រើនជាងយើង រីករាយជាងយើង កាក់កបជាងយើង និយាយតែពីលុយចូលរាល់ថ្ងៃ តើគេមានអាថិកំបាំងអ្វី? នេះជាបុព្វហេតុដែលយើងគួរតែដឹង ។

អាថិកំបាំងនោះ គឺ១-វាជាចំណេះក្នុងកិច្ចការពារទ្រព្យដែលមាន ២-មានវិជ្ជាបង្កើនទ្រព្យដែលមាននោះឱ្យទៅជា២-៣ដង ឬច្រើនដងធំជាងមុន ៣-រស់នៅឱ្យឆ្ងាយពីអំពើក្បត់គ្រួសារ ចូលចិត្តស្រានឹងប្រព្រឹត្តល្បែងពាលា ហើយជាពិសេសទៅទៀតនោះ ៤-បើដឹងថា ជីវភាពខ្លួនធ្លាក់ចុះហើយ ត្រូវរកជំនួយ ពីគ្រោះយោបល់ភ្លាម ។ កិច្ច "ការពារសេដ្ឋកិច្ចគ្រួសារ"ឥឡូវគឺជាវិជ្ជាមួយដែលបច្ចុប្បន្ននេះ "ចាំបាច់"គេត្រូវតែរៀន ពីព្រោះតែមានចោរដែលមានបច្ចេកទេសខ្ពស់ចូលមកលួច រហូតដល់ក្នុងហោប៉ៅក្នុងធានាគារយើងបានគ្រប់ពេលវេលា សូម្បីតែរដ្ឋាភិបាលអាមេរិកាំងយើងហ្នឹងក៏ប្រវ័ញ្ចយកលុយដែលយើងរកបានដោយសុចរិតនោះដែរ ហើយថែមទាំងគម្រាមដាក់គុកយើង មិនចេះចប់មិនចេះហើយទៀតផង។ បើយើងមិនរៀនទេនោះ យើងនឹងធ្លាក់ខ្លួន"ក្រ"ជាស្វ័យប្រវត្តិ បើយើងរកបានរឹតតែច្រើន"ចោរ"នោះលួចកាន់តែក្រៃល ។

លោកភាពគាត់ថា"ខ្ញុំធ្វើការមក៣0ឆ្នាំហើយ សន្សំលុយនៅតាមរោងចក្រខ្ញុំ១៤0១គបបានច្រើនម៉ឺនដុល្លារ ខ្ញុំមានសេចក្តីរីករាយណាស់ ប៉ុន្តែដល់ពេលខ្ញុំត្រូវការលុយ ហើយទៅបើកលុយសន្សំខ្ញុំមកវិញ ស្រាប់តែគេកាត់យកពីខ្ញុំទៅវិញ អស់រាប់ម៉ឺនក្នុងនាមនៃពន្ធដាររដ្ឋ, ដែលធ្វើឱ្យខ្ញុំឈឺចាប់ណាស់ លុយខ្ញុំរកបានដោយញើសឈាមខ្ញុំសោះ មកកាត់យកទាំងស្រស់កាត់រៀងរាល់ខែហើយ កាត់រៀងរាល់ឆ្នាំទៀត មកតាមកាត់ឯលុយសន្សំខ្ញុំទៀត... បើមិនឱ្យទេ ក៏រដ្ឋគេយករួចស្រេចទៅហើយ ប្រកែកក៏មិនបាន... តើឱ្យខ្ញុំធ្វើយ៉ាងណា? លោកភាពត្អូញថា"ខ្ញុំស្ទើរតែស្រែកទ្រហោយំ ..." មែនអ្នកយំទាល់តែសោះទឹកភ្នែក ក៏មិនដោះស្រាយបញ្ហាបាត់លុយនោះដែរ នេះពីព្រោះតែលោកភាពមិនបានសិក្សាពី"ក្បួនការពារលុយ"ដែលគាត់រកបានដោយធមិនោះពីមុនមក។

ឥឡូវនេះនៅឡូវែលយើង អាសេឡិក បានបើកមជ្ឈមណ្ឌលមួយឋិតនៅលេខ៣២៥ ផ្លូវឆែមហ្វៃតឡូវែល មានបើកបង្រៀនពីវិជ្ជាការពារប្រាក់ចំណូលរៀងរាល់ថ្ងៃរបស់លោកអ្នក ហើយមិនត្រឹមតែប៉ុណ្ណោះបង្រៀនដោយឥតយកថ្លៃពីវិធីធ្វើឱ្យប្រាក់ចំណូលទាំងនោះកើនច្រើនឡើងដោយខ្លួនឯងបានទៀតផង... គឺមិនមែនជាចំណេះដឹងថ្មីអ្វីទេ តែជាចំណេះដែលគេមិនសូវបង្រៀនឱ្យគ្រប់គ្នាបានចេះបន្តគ្នា, បើអ្នកមិនស្វះស្វែងរកទេ អ្នកនឹងមិនបានដឹងទេ ។

បើចង់មករៀន សូមចងចាំពេលបង្រៀនពី "ចំណេះថវិការគ្រួសារ": រៀងរាល់ថ្ងៃព្រហស្បតិ៍ ព្រឹកពីម៉ោង១0-១២ ល្ងាចពីម៉ោង ៦-៨យប់, នៅរៀងរាល់ថ្ងៃសៅរ៍ព្រឹក ពីម៉ោង១0-១២ ចាប់ពីដើមខែតុលានេះទៅ។

អាសេឡិកគឺជាអង្គការសមាគមមិនយកកម្រៃ មានទីស្នាក់ការនៅ"មជ្ឈមណ្ឌលសិក្សាឡូវែល" ដ៏កម្រមួយ ដែលមានភារកិច្ចនឹងជួយដល់ថវិការគ្រួសារឱ្យក៏កើនពូនជាសម្បត្តិ កាត់ថ្លៃមិនបាន ពីព្រោះគ្មាននរណានឹងយកពេលមកបង្រៀនចំណេះដ៏ថ្លៃថ្លានេះ ដល់គ្រួសារនឹងកូនចៅខ្មែរយើងនោះទេ គេនឹងទុកឱ្យយើងល្ងង់នៅក្រជារហូតទៅសម្រាប់គេងាយស្រួលនឹងប្រវ័ញ្ច។

"ASALEC -សមាគមអភិវឌ្ឍន៍អាមេរិកាំង-អាស៊ីអគ្នេយ៍"ហៅកាត់ថា"អាសេឡិក"មានសកម្មភាពបង្រៀនវិជ្ជាជីវៈផ្សេងៗទៀត ដោយយកកម្រៃតិចតួច ឬឥតយកថ្លៃសម្រាប់អ្នកមានសិទ្ធទទួលជំនួយពីរដ្ឋ: -វិជ្ជានិយាយភាសា អាមេរិកាំង -វិជ្ជាឯកទេសអេឡិកត្រូនិក - វិជ្ជាឯកទេសប្រើកុំព្យូទ័រ សម្រាប់អ្នកឥតមានការងារធ្វើ... មានសេវាបន្ថែមជាជំនួយសង្គមកិច្ច នឹងជំនួយឯកសាររដ្ឋបាលដល់គ្រួសារ ដល់អ្នកមកដល់ថ្មី មានសេវាបង្រៀនយកប័ណ្ណបើកបរ មានសេវាបង្រៀនចូលសញ្ជាតិអាមេរិកាំង ។ដើម្បីគ្រួសារយើងមានសេវាថ្នាក់សម្រាប់ទទួលកុមាររាល់ថ្ងៃបន្ទាប់ពីម៉ោងរៀនពីម៉ោង៣-៥ល្ងាច ហើយនឹងសេវាដើម្បីសុខភាពមានបង្ហាត់"តៃជី"នៅល្ងាចថ្ងៃសុក្រជូនដល់សហគមន៏យើងទៀតផង ។

ទូរស័ព្ទសម្រាប់ទាក់ទងលេខ ៩៧៨-៩៤២ ១៦៤១ ឬលេខ ៩៧៨- ៤៥៩ ៥៣00, អ៊ីមែល pinsamkhon@gmail.com



# ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**

---

All Care Resources

កម្មវិធីថែទាំសុខភាពសម្រាប់មនុស្សពេញវ័យរបស់គម្រោង អល ខែរីសស (All Care Resources) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីជួយដល់អ្នកជំងឺ និងអ្នកថែទាំដែលរស់នៅជាមួយគ្នានៅក្នុងសហគមន៍តាមរយៈការផ្តល់នូវការគាំទ្រផ្នែកវេជ្ជសាស្ត្រ, ការអប់រំ និងប្រាក់កម្រៃ ។

លក្ខខណ្ឌនៃការដាក់ពាក្យក្នុងកម្មវិធីនេះ :

-អ្នកដែលមានជំងឺត្រូវមានអាយុ១៦ឆ្នាំនិងច្រើនជាងនេះ ហើយត្រូវការការថែរក្សានិងការមើលការខុសត្រូវសម្រាប់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ និងត្រូវមានស្តង់ដាម៉ាស់ហែល ។

-អ្នកថែទាំត្រូវមានអាយុយ៉ាងហោចណាស់១៨ឆ្នាំ រស់នៅក្នុងផ្ទះជាមួយនឹងអ្នកជំងឺតែអ្នកមើលថែនោះមិនត្រូវជាប្រពន្ធ រឺស្វាមី, អ្នកទទួលសិទ្ធជាអាណាព្យាបាលស្របច្បាប់របស់អ្នកជំងឺ ឬជាឪពុកម្តាយដែលមានកូនមិនទាន់ពេញវ័យនោះទេ ។

-អ្នកថែទាំ និងអ្នកជំងឺត្រូវតែរស់នៅជាមួយគ្នា ហើយអ្នកថែទាំត្រូវតែមានលទ្ធភាពមើលថែអ្នកជំងឺពេញ២៤ម៉ោងក្នុង៧ថ្ងៃក្នុងមួយសប្តាហ៍ ។

ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ សូមទំនាក់ទំនង លីនា ឌៀប (Lyna Dep) ដែលស្ទាត់ជំនាញភាសាខ្មែរ តាមរយៈលេខទូរស័ព្ទ ៧៨១-២៤៤-១១១៥ ។

---

COMMUNITY TEAMWORK

# ផ្សារផលិតផលកសិកម្មរបស់កសិករនៅឡូវែល

ថ្ងៃសុក្រ ទី 6 ខែកក្កដា – ថ្ងៃទី 26 ខែតុលា, ម៉ោង 12 pm ដល់ម៉ោង 5 pm
នៅសួន លូស៊ី ឡាខំ ផាក, ផ្លូវ ២៥៨ ម៉ែរីមាក ស្ទ្រីត

circlehealth | Aramark Building Community | fallonhealth



បន្លែស្រស់ៗ, អាហារបំប៉ុងរាងកាយ, ចំណីអាហារ, ផលិតផលដែលធ្វើដោយដៃយ៉ាងពិសេស និងមានអ្វីៗជាច្រើនប្រភេទផ្សេងទៀត

**សប្បាយជាមួយក្រុមគ្រួសារ!**

ការដាក់តាំងបង្ហាញផលិតផលម្ហូបអាហារ, ដន្ត្រី, ល្បែងកំសាន្ត & ការចាប់រង្វាន់!
ទទួលយកអ្នកដែលមាន WIC , ប័ណ្ណចាស់ជរា, ប័ណ្ណSNAP/EBT និងក្រេឌីតកាត

ចំណាយទិញផ្លែឈើ និងបន្លែស្រស់ៗពីកសិដ្ឋាននៅទីផ្សារផលិតផលកសិកម្មរបស់កសិករដោយប្រើប្រាស់ប័ណ្ណ SNAP របស់លោកអ្នក ហើយចំនួននៃការចំណាយទិញរបស់លោកអ្នក នឹងត្រូវបានបូកបញ្ចូលបន្ថែមទៅក្នុងប័ណ្ណ EBT របស់អ្នក!

ត្រូវការជំនួយក្នុងការធ្វើដំណើរមកកាន់កន្លែងលក់? មិនមានបញ្ហា!

| | |
|---|---|
| ទីតាំងមជ្ឈមណ្ឌល ស៊ីនៀ ស៊ីធីជ័រ -- ផ្លូវ 276 Broadway St. | មានឡានមកយកនៅម៉ោង 11:45 |
| ទីតាំងអគ្គាធរលំនៅដ្ឋាន (Housing Authourity)-- ផ្លូវ 21 Salem St. | មានឡានមកយកនៅម៉ោង 12:45 |
| ទីតាំងអគ្គាធរលំនៅដ្ឋាន-- ផ្លូវ 580 Salem St. | មានឡានមកយកនៅម៉ោង 12:45 |

ធ្វើដំណើរត្រឡប់មកវិញពីផ្សារមកកាន់ទីតាំងដែលឡានមកយកនៅម៉ោង 1:40 pm -- មានសេវាដឹកជញ្ជូនគ្រប់កន្លែងលក់ទាំងអស់

រកព័ត៌មានអ្វីៗដែលថ្មីៗរបស់ផ្សារផលិតផលកសិកម្ម សូមចុះឈ្មោះដោយ Sign up ដើម្បីទទួលព្រឹត្តិប័ត្រព័ត៌មានរបស់យើង

សូមចូលទៅកាន់វិបសាយរបស់យើង៖ www.commteam.org/farmers-market

#lowellfarmersmarket #liveatthemarket #LowellMrkt

---

MASSACHUSETTS **HEALTH CONNECTOR** *for Business*

ការផ្តល់ការធានារ៉ាប់រងសុខភាពមិនមែនជាការចំណាយទេ,
វាជាការវិនិយោគមួយនៅក្នុងក្រុមរបស់ខ្ញុំ។

"ហ៊ែលកូណិកទ័រ"សម្រាប់ពាណិជ្ជកម្ម
ផ្តល់នូវការគ្របដណ្តប់បុគ្គលិករបស់អ្នកសមនឹងទទួលបាន,
ក្នុងតម្លៃដែលអ្នកអាចទិញបាន។

- សងថ្លៃបំប៉នសុខភាពល្អ
- ឥណទានពន្ធ
- មិនគិតថ្លៃបន្ថែម



សូមចូលមើលគេហទំព័ររបស់យើងសម្រាប់ជំនួយបន្ថែម: **MAhealthconnector.org/middlesex**

# ការទទួលជំនាញ និងការងារថ្មីៗរបស់ជនអន្តោប្រវេសន៍នៅលីន

ប្រែសម្រួលដោយខ្មែរផុស ស.រ.អា

លីនឡូណណ- កាលពីដើមខែកញ្ញានេះ អភិបាលក្រុង ឆាលី បាកឃ័រ (Charlie Baker) និងអភិបាលរដ្ឋ ថម អេមជី (Tom McGee) បានចូលរួមជាមួយអាជ្ញាធរលំដនៅដ្ឋានលីន, អង្គការឌីវែលឡុបមេន នាយប័រហ៊ូត, អង្គការអភិវឌ្ឍន៏ឱកាសសេដ្ឋកិច្ច លីន និងអង្គការជេវីអេស (JVS) ដើម្បីអបអរការទទួលបានជោគជ័យក្នុងការសិក្សារបស់និស្សិតក្នុងស្រុកផ្នែកភាសាអង់គ្លេសជាន់ខ្ពស់... កម្មវិធីសិក្សាភាសាអង់គ្លេសជាន់ខ្ពស់នេះផ្តល់នូវការបណ្តុះបណ្តាលផ្នែកភាសា និងការផ្តល់



left to right: Andie Salvador, Lynn English for Advancement Student; Mayor Tom McGee; Jerry Rubin, CEO & President of JVS Boston; Tracy Palandijan, CEO and Co-Founder of Social Finance; Nuha Hamimi, Lynn English for Advancement Student; Governor Charlie Baker


Andie Salvador, Lynn English for Advancement Student


Nuha Hamimi, Lynn English for Advancement Student

សេវាកម្មការងារដល់អ្នកនិយាយភាសាអង់គ្លេសបានតិចតួចនៅលីន ដើម្បីបង្កើននូវមុខជំនាញវិជ្ជាជីវៈរបស់ពួកគេ។ ជាមួយគ្នានោះដែរ ក៏មានការអបអរសាទដល់សិស្សានុសិស្សដែលមានជំនាញកាន់តែប្រសើរឡើង និងបានកត់សម្គាល់ពីការរួមចំណែកដ៏មានតំលៃដល់ការងារថ្មីរបស់ពួកគេ។

អភិបាលក្រុង ឆាលី បាកឃ័រ បាននិយាយថា "ចាប់តាំងពីចូលកាន់តំណែងជារដ្ឋបាលក្រុង ខុតការល័យរបស់យើងឱ្យអធិភាពដល់ការវិនិយោគលើការអភិវឌ្ឍកម្លាំងធាធានមនុស្ស ដើម្បីជួយដល់ពលកររនៅរដ្ឋរដ្ឋម៉ាសាជូសេត ទទួលបាននូវជំនាញដែលពួកគេត្រូវការសម្រាប់ទទួលបានជោគជ័យក្នុងវិជ្ជាជីវៈរបស់ខ្លួន។ "គម្រោងឆ្ពោះទៅរកការធ្វើឱ្យប្រសើរឡើងឱកាសសេដ្ឋកិច្ច (The Pathways to Economic Advancement Project) បានជួយផ្តល់នូវការបណ្តុះបណ្តាលការងារ តាមរយៈកម្មវិធីដែលមានប្រសិទ្ធភាពដែលអាចជួយកាត់បន្ថយនូវគំលាបនៃជំនាញ និងជួយផ្តល់ឱកាសអភិវឌ្ឍន៏សេដ្ឋកិច្ចទូទាំងរដ្ឋម៉ាសាជូសេតទាំងមូល"។

ការងារជាច្រើនដែលសិស្សដែលបានទទួលការបណ្តុះបណ្តាល់ និងទទួលបានការងារ គឺផ្នែកសុខភាព និងការងារដែលពាក់ព័ន្ធផ្សេងៗទៀត។ លោក ស៊ី យូលិនដា ខ្យូរេត (C. Yolanda Curet) អ្នកជំនាញផ្នែកបុគ្គលិកនៃមជ្ឈមណ្ឌលវេជ្ជសាស្រ្តន័ស ស័រ (North Shore) បាននិយាយថា "ក្នុងនាមជាអ្នកផ្តល់សេវាថែទាំសុខភាពធំជាងគេនៅន័សស័រ យើងកំពុងស្វែងរកបុគ្គលិកដែលមានទេពកោសល្យដើម្បីបំពេញការងារនៅមុខតំណែងជាច្រើន"។ លោកបានលើកឡើងថា "សិស្សានុសិស្សដែលមកពីកម្មវិធីសិក្សាភាសាអង្គេសជាន់ខ្ពស់មាន

តទៅទំព័រទី១០






# ការទទួលរង្វាន់ពីគុណភាពនៃសេវាថែទាំអ្នកជំងឺរបស់មណ្ឌលសុខភាពសហគមន៍ឡូវែលពី The Joint Commission

បកប្រែដោយ កូយ សុខារ័ត្ន

ឡូវែល-មជ្ឈមណ្ឌលសុខភាពសហគមន៍ឡូវែល(Lowell CHC) បានទទួលរង្វាន់ហ្គូលសៀលអោសអាប់ប្រូវែល (Gold Seal of Approval®) ពីអង្គភាព ជឹក ជាញ់ ខំមីសសិន (The Joint Commission) ដោយបញ្ជាក់ពីការទទួលស្គាល់ជាផ្លូវការគុណភាពនៃការថែទាំសុខភាពប្រភេទអ្នកជំងឺមិនសំរាកនៅមន្ទីពេទ្យរបស់មន្ទីរពេទ្យមួយនេះ ដោយការគោរពទៅតាមស្តង់ដារដែលត្រូវបានទទួលស្គាល់ទូទាំងពិភពលោក។ រង្វាន់ហ្គូលសៀលអោសអាប់ប្រូវែល គឺជានិមិត្តសញ្ញានៃគុណភាពដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់មជ្ឈមណ្ឌលសុខភាពក្នុងការផ្តល់ការថែទាំអ្នកជំងឺប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

មជ្ឈមណ្ឌលសុខភាពសហគមន៍ឡូវែល បានឆ្លងកាត់ការត្រួតពិនិត្យនៅនឹងកន្លែងរយៈពេល៣ថ្ងៃយ៉ាងម៉ត់ចត់ដោយមិនបានប្រកាសជាសាធារណៈកាលពីខែឧសភា។ ក្នុងអំឡុងពេលនៃការពិនិត្យឡើងវិញ ក្រុមអ្នកត្រួតពិនិត្យរបស់អង្គភាព The Joint Commission រួមដែលមានជំនាញខាងផ្នែកថែរក្សាសុខភាព បានវាយតម្លៃការអនុវត្តតាមស្តង់ដារនៃការថែទាំដែលទាក់ទងទៅនឹងការប្រើប្រាស់ថ្នាំសណ្តំ រឺថ្នាំស្ពឹក, ការចាក់ថ្នាំបង្ការ, ការគ្រាប់គ្រង់ឱសថ និងការអប់រំនិងការបណ្តុះបណ្តាល



អ្នកជំងឺ។ អង្គភាព The Joint Commission ជាទូទៅគឺធ្វើការត្រួតពិនិត្យឡើងវិញនៅជារៀងរាល់បីឆ្នាំម្តង។

តទៅទំព័រទី ១៤

# Lowell CHC AWARDED AMBULATORY HEALTH CARE ACCREDITATION FROM THE JOINT COMMISSION

-Translation by Sokharath Koy, KhmerPost USA

LOWELL, MA, – Lowell Community Health Center (Lowell CHC) has earned The Joint Commission's Gold Seal of Approval® for Ambulatory Health Care Accreditation by demonstrating continuous compliance with its rigorous, nationally recognized standards. The Gold Seal of Approval® is a symbol of quality reflecting the health center's commitment to providing safe and effective patient care.

Lowell CHC underwent a rigorous, unannounced, three-day onsite survey on in May. During the review, a team of Joint Commission surveyors with expertise in ambulatory health care evaluated compliance with ambulatory care standards related to areas including coordination of care, monitoring for procedures that involve use of sedation or anesthesia, infection prevention and control, management of medications, and patient education and training. The Joint Commission review takes place every three years.

Established in 1975, The Joint Commission's Ambulatory Health Care Accreditation Program encourages high-quality patient care in all types of freestanding ambulatory care facilities. Today, the Ambulatory Health Care Accreditation Program serves 2,100 ambulatory care providers, with more than 8,500 sites of care, which, in turn, serve more than 83 million patient visits annually.

"Joint Commission accreditation provides Continued to Page 14

**KhmerPost USA, LLC**
**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

**ផ្សាយពាណិជ្ជកម្ម Advertising**
អគ្គនាយក សុបិន្ត ពិន Soben Pin, *Co-Founder/Publisher*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

**អ្នកនិពន្ធ Editorials**
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Co-founder/Editor*
(978) 942 - 1641 | rogerpin@khmerpost.us
កាវីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស Staff Writer/Translator
Sokharath Koy
ច្នៃសោភ័ណភាពកាសែត Design Artist
Heng Chhunleng
ជំនួយការរដ្ឋបាល Office Coordnator
Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

Follow us: Facebook | Twitter KhmerpostUSA

LOWELL COMMUNITY HEALTH CENTER

Lowell CHC Metta Health Center is now located on the 3rd floor of 161 Jackson Street



978.937.9700 | www.lchealth.org

តមកពីទំព័រទី ០៨

# ការទទួលជំនាញ និងការងារថ្មី...

ជំនាញដែលយើងត្រូវការសម្រាប់បំពេញការងារ និងតួនាទីសំខាន់ៗនៅក្នុងសេវាកម្មគាំទ្ររបស់យើង។ ហើយនៅថ្ងៃណាមួយ ពួកគេនឹងត្រៀមខ្លួនរួចជាស្រាច់ដើម្បីបន្តការសិក្សាបន្ថែមទៀង"។

កាលពីខែមករា លោកអភិបាលរដ្ឋ ថម អេមជី បានជំរុញឱ្យគម្រោងកម្មវិធីនៅលីននេះជួយសម្របសម្រួលដល់អ្នកស្មាកចិត្តជាច្រើនក្នុងកិច្ចការជួយផ្សព្វផ្សាយនូវអ្វីដែលហៅ "រៀនច្រើនរកចំណូលច្រើន" ឱ្យបានគ្រប់កន្លែងប្រកបដោយជោគជ័យ... យុទ្ធនាការផ្សព្វផ្សាយនេះ បានជួយឱ្យយុវជនមកចុះឈ្មោះសិក្សាកាន់តែច្រើនឡើង និងបានភ្ជាប់ពួកគេជាមួយនិយោជករួមទាំងភោជនីយដ្ឋាន, ក្រុមហ៊ុនម្ហូបអាហារ, អង្គការថែទាំសុខភាព និងបណ្ណាសាលានៅលីនជាដើម។

លោកអភិបាលរដ្ឋ ថម អេមជី ក៏បានមានប្រសាសន៍ថា "កម្មវិធីសិក្សាភាសាអង់គ្លេសជាន់ខ្ពស់នេះ គឺជាផែនទីចង្អុលផ្លូវមួយឆ្ពោះទៅរកការជោគជ័យ។ យើងមានក្ដីរំភើបរីករាយក្នុងការសហការធ្វើជាដៃគូ ដែលវាពិតជាបានជួយដល់ប្រជាជន និងអាជីវកម្មរបស់យើង។ ប្រវត្តិនៃរឿងរ៉ាវនៃជនអន្តោប្រវេសន៍ គឺជាចំណុចដ៏សំខាន់ណាស់នៃប្រទេសរបស់យើង ហើយយើងមានមោទនភាពដែលបានឃើញរឿងនេះកើតឡើងនៅលីន"។

អង្គការជេវ:អេសបានកំពុងដឹកនាំនូវគម្រោងកម្មវិធីនេះ ហើយជឿជាក់ថា ភាពជាដៃគូរបស់សហគមន៍ ដូចជាកម្មវិធីសិក្សាភាសាអង់គ្លេសជាន់



left to right: Mayor Tom McGee; Jerry Rubin, CEO & President of JVS Boston; Tracy Palandijan, CEO and Co-Founder of Social Finance; Governor Charlie Baker

ខ្ពស់នេះ គឺជាគំរូមួយសម្រាប់សហគមន៍នៅទូទាំងរដ្ឋម៉ាសាជូសេត។

លោក ជឺរី រូបីន ឡូរេយ ប្រ៊ិនធ នាយកប្រតិបត្តិ និងជាប្រធានអង្គការ JVS បានមានប្រសាន៍ថា "យើងបានបង្កើនសេវាកម្មអភិវឌ្ឍន៍កម្លាំងធនធានមនុស្សរបស់យើងពីការិយាល័យកណ្ដាលរបស់យើងនៅក្រុងបូស្តុន រហូតដល់ក្រុង ហ្គេតវ៉េយ៍ ដូចជាក្រុងលីន ដែលបាននាំមកនូវកម្មវិធីដែលមានគុណភាពខ្ពស់របស់យើងឆ្ពោះទៅនឹងរកកំណើនសេដ្ឋកិច្ចក្នុងតំបន់"។ ក្នុងរយ:ពេលមួយឆ្នាំកន្លងមកនេះ យើងបានផ្ដល់ការងារដល់និស្សិតលីនជាង៧០ នាក់ក្នុងកន្លែងការងារថ្មី ឬល្អប្រសើរជាងមុន ដោយបានជួយបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ និងជួយបំពេញនូវមុខតំណែងនៅក្នុងអាជីវកម្មតូចតាចសំខាន់ៗជាច្រើន"។

កម្មវិធីសិក្សាភាសាអង់គ្លេសជាន់ខ្ពស់នេះ គឺជាលទ្ធផលនៃម៉ូឌែលដែលមានលក្ខណ:ឆ្នៃប្រឌិតដែលត្រូវបានគេស្គាល់ឈ្មោះថា "Pay for Success"។ លោក ត្រាស៊ី បាលិនជេន (Tracy Palandjian) នាយកប្រតិបត្តិ និងជាសហស្ថាបនិករបស់អង្គការសូស្យូល ហ្វាយនិន (Social Finance) បានមានបញ្ជាក់ថា "ថ្ងៃនេះយើងកំពុងតែអបអរនៅនឹងលទ្ធផលនៃម៉ូដែលកម្មវិធីដែលមានឈ្មោះថា "Pay for Success" នៅកន្លែងធ្វើការនៅក្នុងសហគមន៍របស់យើង"។ ជាមួយនឹងភាពជាដៃគូតែមួយគត់នេះក្នុងចំណោមដៃគូរទាំងអស់ យើងកំពុងជួយដល់ជនអន្តោប្រវេសន៍ឱ្យទទួលបានការងារល្អ, ធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូលរបស់ពួកគេ និងកសាងជីវិតរបស់ពួកគេនៅក្រុងលីននេះ"។

អូដាលីសាដែលជាសិស្សបានបញ្ចប់ការសិក្សាពីកម្មវិធីសិក្សាភាសាអង់គ្លេសជាន់ខ្ពស់នេះ បានឱ្យដឹងថា "ខ្ញុំបានចុះឈ្មោះក្នុងកម្មវិធីនេះ ព្រោះខ្ញុំចាំបាច់ត្រូវរៀនភាសាអង់គ្លេស ហើយស្វែងរកការងារដែលល្អប្រសើរជាងមុខ"។កម្មវិធីនេះគឺជាកម្មវិធីដ៏ល្អបំផុតមួយ ហើយគ្រប់គ្នាគួរតែចុះឈ្មោះសិក្សា។ ភាសាអង់គ្លេសរបស់ខ្ញុំបានរីកចម្រើនច្រើន ហើយឥឡូវនេះខ្ញុំមានការងារដែលមានប្រាក់ខែខ្ពស់!"។

កម្មវិធីសិក្សាភាសាអង់គ្លេសជាន់ខ្ពស់នេះ គឺកើតចេញពីគម្រោងឆ្ពោះទៅរកការធ្វើឱ្យប្រសើរឡើងឱកាសសេដ្ឋកិច្ច (The Pathways to Economic Advancement Project)។ គម្រោងនេះ ត្រូវបានអនុវត្តន៍ដោយរដ្ឋម៉ាសាជូសេត ដែលមានតំណាងដោយការិយាល័យរដ្ឋបាន និងហិរញ្ញវត្ថុ, ការិយាល័យអភិវឌ្ឍន៍ការងារ និងពលម្ម និងការិយាល័យអប់រំ ដោយមានការចាប់ដៃគូរពីសំណាក់អង្គការជេវីអេស (JVS), អង្គការសូស្យូល ហ្វាយនិន, GPL និងក្រុមហ៊ុនមួយចំនួនទៀត។









## ផ្តើមសេចក្តី

អារម្ភកថា

យើងសូមជូនរឿងថ្មីមួយទៀត គឺរឿង"កុមារ យោធិន្ទ"ជាប្រវត្តិកុមារប្រមាណជា១ពាន់នាក់ ដែលបានចូលទៅបំរើក្នុងកងទ័ពតាំងពិអាយុ១០ឆ្នាំ នៅសាលារៀនមួយដែលកងខេមរភូមិន្ទបាន បង្កើតឡើងបន្តពីអាណានិគមបារាំងក្នុងបំណងជួយចិញ្ចឹមកូនរបស់កងទ័ពបង្ហាត់បង្រៀនមុខវិជ្ជាដែល ឪពុករបស់គេស្រឡាញ់ចូលចិត្តនឹងបានបូជាជីវិត ដើម្បីមាតុភូមិរបស់គេថែមទៀត។

ជារឿងពិតរបស់យុវជនមួយក្រុមរស់នៅដាច់ពីការថ្នាក់ថ្នមរបស់ឪពុកម្តាយមិនដូចក្មេង ឯទៀត គេចិញ្ចឹមកុមារទាំងនោះ ក្រោមវិន័យតឹងរឹងនៃកងទ័ពបង្ហាត់ហ្វឹកហ្វឺននឹងរៀនសូត្រវិជ្ជាចម្បាំងតាំងតែពីនៅតូច តែសាធារណជនមិនសូវដែលដឹងថា"សាលានោះជាអ្វី? បង្ហាត់បង្រៀនរបៀបណា? នឹងស្គាល់ថា ជាអ្វីនោះទេ" ក្រៅតែពីអ្នកនៅក្នុងក្រុងជាមួយនឹងអ្នកមិនឆ្ងាយពីបន្ទាយនៃកូនទាហ៊ានទាំងនោះ តែប៉ុណ្ណោះដែលស្គាល់ ហើយឱ្យឈ្មោះថា"ពួកក្មេងហ្វូង" ដែលជាឈ្មោះបកប្រែពីពាក្យបារាំងមកថា"Les enfants de troupe"។

# សាលាកងកុមារយោធិន្ទការមកដល់នៃសិស្សថ្មី (ត)

**ពិន សំខុន**

**ភាគ១ - សាលាកងកុមារយោធិន្ទ ការមកដល់នៃសិស្សថ្មី (ត)**

ឆ្នាំ១៩៦៣ សាលាកុមារយោធិន្ទបានប្តូរមេបញ្ជាការពីលោកអនុសេនីយឯក នង ញ៉ែង មកលោកមេបញ្ជាការវ័យក្មេងស្គមខ្ពស់សង្ហារចារឹកមាំទាំ ប្រកបដោយវិន័យ អនុសេនីទោ ទឹម ថូ ។ នៅបន្ទាយក្រោមមិនយូរប៉ុន្មាន លោក ទឹម ថូ ក៏ប្តូរបន្ទាយក្រោមទៅកាន់បន្ទាយធំទូលាយមួយនៅផ្នែកខាងមុខជាប់ផ្លូវធំ នឹងទន្ទឹមគ្នានឹងអាគិចៅហ្វាយខេត្តកំពុងចាមតែម្តង ដោយលោកមេបញ្ជាការថ្មីនេះ មានភរិយាជាក្រុមគ្រួសារមេទ័ពធំម្នាក់នៅភ្នំពេញ គឺឧត្តមសេនីយ ស្រី សាម៉ន នៃទីបញ្ជាការជាន់ខ្ពស់របស់កងទ័ព។ នៅទីថ្មីនោះយ៉ាងឆាប់រហ័ស មានសោភ័ណ្ឌភាព នឹងជាកន្លែងហាត់ហ្វឹកហ្វឺនប្រកបដោយវិន័យជាសាលាពិសេសមួយ ហើយក៏ក្លាយជាក្លោងទ្វារកិត្តិយសមួយរបស់សាលាកងទ័ពខ្មែរ ។

សាលាកុមារយោធិន្ទមានសិស្សកីឡាករគ្រប់ផ្នែកមានតាំងពីក្រុមបាល់ទាត់ ក្រុមបាល់ទះ ក្រុមបាល់បោះ ក្រុម យូដូការ ចូលរួមប្រកួតមានជោគជ័យច្រើនកន្លែងក្នុងចំណោមសិស្សនឹងនិស្សិតនៃវិទ្យាល័យនានា ណាប្រទេសកម្ពុជា, គេនៅចាំថា នៅពេលដង្ហែរក្បួនកងទ័ពនៃថ្ងៃបុណ្យឯករាជ្យនៅមុខព្រះបរមរាជវាំងម្តងៗជារៀងរាល់ឆ្នាំ សាលាកងកុមារយោធិន្ទតែងតែនាំមុខក្បួនព្យួរយាត្រានៃកងខេមរៈភូមិន្ទ មិនដែលខាន នឹងមិនដែលធ្វើឱ្យមេបញ្ជាការខកចិត្តម្តងណា



សិស្សកុមារយោធានៅដាឡាត់កាលពីជំនាន់អាណានិគមបារាំង

ឡើយ។ សិស្សកុមារយោធិន្ទកាន់តែចំនួនច្រើនបានប្រឡងប្រជែងជាប់ចូលរៀននៅវិទ្យាល័យព្រះសីហនុកំពុងចាម បើមិនដូច្នោះទេពួកគេក៏អាចនៅរៀនវិទ្យាល័យក្នុងបន្ទាយ ក៏បានដូចគ្នា តែគុណភាពមិនដូចនៅរៀនសាលាខាងក្រៅនោះទេ។ ថែមពីលើនេះទៀត ក៏មានសិស្សដែលបានប្រឡងជាប់ចូលជាសិស្សសាលានាយទាហ៊ាន EOA ក៏កាន់តែចំនួនច្រើនឡើងជាលំដាប់។

ដូចលោកកុម្មង់ដង ម៉ាំង ពិន នៃបន្ទាយ"គុយស្មេ"ដែលបានបញ្ជូនកូនប្រុសដល់ទៅ៣នាក់ទៅសាលាកុមារយធិន្ទ គឺ សំផុន ចូលនៅឆ្នាំ១៩៥២-សំខុន នឹង សំផាន់ នៅឆ្នាំ១៩៥៩... ម្តងបន្តិចមេទ័ពតូចធំៗ ក៏បញ្ជូនកូនរបស់ខ្លួនឱ្យមកទទួលការហាត់ហ្វឹកហ្វឺនវិជ្ជាទាហ៊ានតាំងពីកុមារដូចកូនទាហ៊ានសក្តិតូចដែរ មានកូនលោកសក្តិ៥មាស ហ៊ុល គឺកុមារយោធិន្ទ ហ៊ុល សំបូរ - ហ៊ុលសម្បត្តិ, កូនសក្តិ៥ ប៊ួរ ហ៊ល គឺកុមារយោធិន្ទ ហ៊ល ប៊ុនធឿន មិនតែប៉ុណ្ណោះ មានទាំងព្រះញាតិវង្សខ្សែរព្រះអង្គឌួងអ្នកអង្គម្ចាស់ ឌួង ដារាវង្ស, ខាងខ្សែរស៊ីសុវត្ថិ មានអ្នកអង្គម្ចាស់ ស៊ិសុវត្ថិ ខារម៉ា



លោក សោម ផុស អតីតកុមារយោធា កាលពី៥០ឆ្នាំមុន

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ផុណ្ណារ៉ាក់, លើសពីនេះទៅទៀត មានព្រះអង្គម្ចាស់ព្រះរាជបុត្រនាយករដ្ឋមន្ត្រីខ្សែរនរោត្តមព្រះអង្គម្ចាស់នរោត្តម សុរិយាវង្ស - ព្រះអាណុច នរោត្តម អាទិច្ចវង្ស, លើសពីអ្វីទាំងអស់ សូម្បីតែព្រះរាជបុត្រជារាជទាយាទក៏ចូលមកសិក្សាសាលាកុមាយោធិន្ទកំពង់ចាមដែរ គឺព្រះអង្គម្ចាស់នរោត្តម យុវនាថ នឹងព្រះ-អណុជនរោត្តមខេមានុរក្សទាំងពីរព្រះអង្គបញ្ចប់ការសិក្សានៅប្រទេសចិនភ្លាម ក៏ត្រូវបញ្ជូនឱ្យមកទទួលការអប់រំវិន័យទាហ៊ាន នៅសាលាកុមាយោធិន្ទកំពង់ចាមតែម្តង ដោយសារតែកេរឈ្មោះនៃសាលាកុមារយោធា បានក្លាយជាសាលាគំរូសម្រាប់អប់រំអនាគតនៃកងទ័ពនោះឯង។

វត្តមាននៃកុមារយោធិន្ទជាព្រះរាជបុត្រនឹងជាកូនអ្នកធំ ហាក់ដូចជាមានជះឥទ្ធិពលពីឪពុកម្តាយជាអ្នកធំៗនៃកម្ពុជាប៉ុន្តែលោកមេបញ្ជាការទឹម ថូ បានគ្រប់គ្រងវិន័យកងទ័ពនៅក្នុងបន្ទាយបានប្រសើរហួសការស្មាន។

ខុសគ្នាពិអ្នកខាងលើកុមារយោធិន្ទឆ្នាំ១៩៦៦ សោម ផុស អត្តលេខ៨៦៧ បាននិយាយពីការជ្រើសរើសរបស់ខ្លួនថា"ខ្ញុំជាប្អូនប្រុសប្អូនទី៣ ដែលបានក្លាយជាសិស្សកុមារយោធិន្ទមុនបងៗរបស់ខ្លួននៅអាយុ១១ឆ្នាំពីព្រោះឪពុករបស់ខ្ញុំមើលឃើញថា ខ្ញុំជាក្មេងឥតប្រយោជន៏ហើយមិនឆ្លាតដូចបងៗទេ... ដូច្នេះគឺខ្ញុំនេះហើយដែលត្រូវបញ្ជូនទៅសាលាកុមារយោធិន្ទមុនគេ តែដោយសារតែឪពុកខ្ញុំជាកូនទាហ៊ានដែលមានរូបរាងសង្ហារនៅបំរើតែមេទ័ពធំៗ គាត់បានទៅជួបឧត្តមសេនីយលន់ នល់ សុំឱ្យលោកអនុគ្រោះឱ្យកូនរបស់គាត់ម្នាក់បានចូលជាសិស្សកុមារយោធិន្ទ...មិនត្រឹមតែលោកប្រមុខមេទ័ពខ្មែរយល់ព្រមឱ្យខ្ញុំចូលជាសាលាកុមារយោធិន្ទតែប៉ុណ្ណោះទេ ថែមទាំងបានទទួលការតម្លើងឋានន្តរសក្តិពីទាហ៊ាន"ដឺស៊ាមក្លាស 2eme.classe ទៅជាប្រឹមិញ្ញេក្លាស 1ere Classe" ឡើងពាក់សក្តិ"បេប"ក្នុងពេលជាមួយគ្នា ដោយសារបានបំរើមេទ័ពធំៗច្រើនឆ្នាំប្រកបដោយភក្តីភាពផង។ ខ្ញុំបានចូលជាកុមារយោធាក៏បែរជារៀនបានប្រសើរ មានសុខភាពល្អ មានប្រាជ្ញាក៏ភ្លឺថ្លា មិនយូរប៉ុន្មានខ្ញុំក៏បានប្រឡងចូលវិទ្យាល័យព្រះសីហនុ ចំណាត់ថ្នាក់លេខ១១ ក្នុងចំណោមសិស្សប្រឡងជាប់៨០០នាក់ ជាពិសេសក្នុងចំណោមនិស្សិត៣០០នាក់ ដែលបានចូលរៀនដោយមិនបង់ថ្លៃ ហើយបានក្លាយជានិស្សិតស្លៀកពាក់ជាសិស្សកុមារយោធាដើរជាជួរជាក្បួនយ៉ាងសង្ហារនឹងយ៉ាងខុសពីអ្នកឯទៀតៗទៅរៀន មិនដូចជាសិស្សដទៃឯទៀតដែលសុទ្ធតែស្លៀកពាក់ជា"ស៊ីវិល"នោះទេ គឺឯកសណ្ឋានខោគគី អាវសស្បែកជើងសង្រែកឬស្បែកជើងបាតា...។

(នៅមានត)

## ជម្រាបមកលោក សុងធុល ហ្វែណង់ដេស

ខ្ញុំបានសរសេរអត្ថបទមួយដែលមានឈ្មោះថា"ប្រៀបធៀបរបបកម្ពុជាសព្វថ្ងៃទៅ នឹងរបបប៉ុល ពត" នៅក្នុងនោះខ្ញុំបានដាក់ឈ្មោះ លោក សុងធុល ហ្វែណង់ដែស ជាសាក្សី ដោយមិនបានទទួលការយល់ព្រមពីសាមីខ្លួនជាមុនពេលផ្សាយ ដែលខ្ញុំសូមអភ័យទោស ដូច្នេះហើយអត្ថបទនោះនៅក្រោមការទទួលខុសត្រូវរបស់ខ្ញុំទាំងស្រុង។ ពិន សំខុន

Bonjour,

J'ai reçu votre journal 256 dans lequel un article sans mon consentement a été publié. La responsabilité de son contenu n'engage que KhmerPost.

Tous mes articles en Français sont publiés sur mon compte Facebook. Ils sont ouverts au public.

Cordialement,

Songthoul Fernandez

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare

Home Care Agency

Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារ៉ាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**បើចង់អាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មានវេហ៊ិលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# លិខិតជម្រាបបុណ្យ១០០ថ្ងៃ

លោក ពិន សំខុន ភរិយានឹងបុត្រ សូមជម្រាបជូនដំណឹងដល់ក្រុមគ្រួសារនឹងញាតិមិត្រ ពីពិធីបុណ្យគម្រប់១០០ថ្ងៃ នៃមរណភាពតាមគន្លងព្រះពុទ្ធសាសនា របស់លោក ពិន សំផុន ត្រូវជាបងប្រុស ដែលបានចូលមរណភាព ក្នុងជន្មាយុ៧៥ឆ្នាំ កាលពីថ្ងៃទី១២មិថុនា ២០១៨ នឹងបុណ្យមរណភាពគម្រប់៤៩ថ្ងៃ តាមគន្លងសាសនា"មុយស៊ុលម៉ង់"របស់បងថ្លៃស្រីលោកស្រី អាហ៊ីម៉េត អាលីស៊ីហ្វា ភរិយាលោកពិន សំផុន ទទួលមរណភាពក្នុងជន្មាយុ៦៣ឆ្នាំ កាលពីថ្ងៃទី២សីហាឆ្នាំ២០១៨ នៅ"សង់តឺលូឡេវីញ"នៃប្រទេសបារាំង ។

ពិធីនេះនឹងប្រារព្ធឡើងនាថ្ងៃ អាទិត្យទី១៤ខែតុលា២០១៨ ពីម៉ោង៩ព្រឹក-ដល់ម៉ោង១២ថ្ងៃត្រង់ នៅ"វត្តខ្មែរសាមគ្គីសន្តិការាម" ស្ថិតនៅ 85 Tyngboro Rd. North Chelmsford, MA 01863 នៅក្បែរទីក្រុងឡូវែលនៃសហរដ្ឋអាមេរិក ។

ក្នុងពិធីបុណ្យនោះ នឹងមានប្រារព្ធពិធីសូត្រមន្ត បង្សុកូល នឹងរាប់បាត្រ ឧទ្ទិសដល់ព្រលឹងនៃសព បន្ទាប់មកមានការប្រគេនចង្ហាន់ព្រះសង្ឃ ។ នៅកិច្ចបញ្ចប់បុណ្យ មានការពិសារភោជនាហាររួមជាមួយភ្ញៀវជាពុទ្ធបរិស័ទទាំងអស់គ្នា នៅម៉ោង១២ផង ។



ពិន សំផុន និងភរិយា


# ការិយាល័យច្បាប់

រ៉ូសា និង តាំង



Francisco J. Rosa, Esq.

មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា



Andrew ´Bunna´ Taing, Esq.

មេធាវី អែន ឌ្រីវប៊ុណ្ណា តាំង

Law Office of

Rosa & Taing

ATTORNEY AT LAW

| SERVICES | កំណាងក្ដីដូចខាងក្រោម |
|---|---|
| Auto Accidents/ Personal Injury | គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| Bankruptcy | ក្ស័យធន |
| Immigration | អន្តោប្រវេសន៍ |
| Consumer Protection | ការពារអតិថិជន |
| Real Estate Closings/Disputes | វិវាទសំផ្នែកអចលនវត្ថុ |
| Divorces Child Custody | លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851

Phone: **978-458-0934** | at@rosataing.com



# Red Rose

ភោជនីយដ្ឋាន RESTAURANT

ក្លាបក្រហម ម្ចាស់ថ្មី -ម្ហូបឆ្ងាញ់

*Pailin Plaza*
*716 Middlesex St. Ste 1*
*Lowell, MA 01851*

អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm



បាយសាច់ជ្រូកពងទាចៀន





មីកន្ទាំង

* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400





បបរគ្រឿង





# CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកឺខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការរក្សាឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY
INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com

សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

តមកពីទំព័រទី ០៩

## ការទទួលរង្វាន់ពីគុណភាពនៃ...

ដោយបង្កើតឡើងក្នុងឆ្នាំ១៩៧៥ កម្មវិធីនៃការទទួលស្គាល់គុណភាពនៃការថែទាំសុខភាពប្រភេទអ្នកជំងឺមិនសំរាកនៅមន្ទីរពេទ្យ (Ambulatory Health Care Accreditation Program) របស់អង្គភាព The Joint Commission បានជំរុញលើកទឹកចិត្តឱ្យកាន់តែមានការយកចិត្តទុកដាក់ការផ្តល់សេវាថែទាំអ្នកជំងឺដែលមានគុណភាពខ្ពស់គ្រប់ផ្នែករបស់មជ្ឈមណ្ឌលសុខភាពសហគមន៍ឡូវែលដោយមិនគិតថ្លៃ។ បច្ចុប្បន្នកម្មវិធីនៃការទទួលស្គាល់គុណភាពនៃការថែទាំសុខភាពប្រភេទអ្នកជំងឺមិនសំរាកនៅមន្ទីរពេទ្យ ធ្វើការជាមួយនឹងមន្ទីរពេទ្យដែលមើលថែទាំអ្នកជំងឺមិនសំរាកនៅមន្ទីរពេទ្យចំនួន២១០០ ដែលមានទីតាំងច្រើនជាង ៨៥០០កន្លែងដែលអាចបំរើសេវាដល់អ្នកជំងឺជាង ៨៣លាននាក់ជារៀងរាល់ឆ្នាំ។

លោក មីឆែល កុលស៊ីគី នាយកប្រតិបត្តិនៃគម្រោងកម្មវិធីទទួលស្គាល់គុណភាពអប់រំសុខភាព បានមានប្រសាសន៍ថា "ការទទួលស្គាល់ជាផ្លូវការរបស់ The Joint Commission គឺផ្តល់ឱ្យអង្គការថែរក្សាសុខភាពជាមួយ និងការធានារ៉ាប់រង និងការណែនាំដើម្បីឱ្យផ្តល់សេវាថែទាំមានកំរិតខ្ពស់បំផុត និងសុវត្ថិភាពដល់អ្នកជំងឺគ្រប់ផ្នែកទាំងអស់ ចាប់ពីការបង្កើនការអប់រំដល់បុគ្គលិករហូតដល់ការអនុវត្តការថែទាំងដែលឈានមុខ"។ លោកបានបន្តដែរថា "យើងសូមសរសើរដល់មជ្ឈមណ្ឌលសុខភាពសហគមន៍ឡូវែល និងបុគ្គលិកទាំងអស់ដែលបានបង្ហាញនូវការប្តេជ្ញាយ៉ាងច្បាស់លាស់ដល់ការផ្តល់សេវាថែរក្សាសុខភាពដែលមានគុណភាពនិងសុវត្ថិភាពដល់អ្នកជំងឺ។ យើងសូមថ្លែងអំណរគុណដល់ Lowell CHC ចំពោះការប្តេជ្ញាចិត្តចំពោះសុវត្ថិភាពអ្នកជំងឺ និងការទុកចិត្ត The Joint Commission ដើម្បីជួយអ្នកទាំងអស់គ្នា។

លោកស្រី ស៊ូសេន វេស ឡេវីន ( Susan West Levine ) នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសុខភាពសហគមន៍ឡូវែល បានមានប្រសាសន៍ថា "យើងមានកិត្តិយសដោយបានទទួលស្គាល់ជាផ្លូវការសេវាថែទាំរបស់យើងពីសំណាក់ The Joint Commission។ លោកស្រីបានបន្តទៀតថា "ខ្ញុំសូមសសើរដល់បុគ្គលិកដែលខិតខំធ្វើការងាររបស់យើងពីគ្រប់ផ្នែកទាំងអស់ និងសមាជិកក្រុមប្រឹក្សាភិបាលរបស់យើងដែលបានបន្តធ្វើការងារជាមួយគ្នាដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាថែទាំដល់អ្នកជំងឺនៅក្នុងសហគមន៍របស់យើង" ។

ស្តង់ដានៃការថែទាំសុខភាពអ្នកជំងឺដែលមិនស្នាក់នៅមន្ទីរពេទ្យរបស់ The Joint Commission គឺត្រូវបានបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយអ្នកជំនាញនឹងស្ថាប័នផ្តល់សេវាថែទាំសុខភាព, អ្នកជំនាញក្នុងការត្រួតពិនិត្យ និងអ្នកជំងឺ ។

ស្តង់ដាទាំងអស់គឺផ្អែកទៅលើការសិក្សាតាមបែបវិទ្យាសាស្ត្រ និងមានការឯកភាពពីសំណាក់អ្នកជំនាញក្នុងគោលបំនង ដើម្បីជួយដល់គ្រប់ស្ថាប័នសុខភាពទាំងអស់ក្នុងការវាស់វែង, វាយតម្លៃ នឹងធ្វើអោយប្រសើរឡើងក្នុងការអនុវត្តន៏ការផ្តល់សេវាថែទាំរបស់ខ្លួន។

Continued from page 09

## Lowell Community Health Center...

ambulatory care organizations with the assurance and guidance to provide the highest level of care and patient safety in a variety of areas, from the enhancement of staff education to the demonstration of leading practices within the ambulatory setting," said Michael Kulczycki, M.B.A., CAE, executive director, Ambulatory Health Care Accreditation Program. "We commend Lowell CHC and its staff for demonstrating a clear commitment to patient safety and quality care. We thank Lowell CHC for tits commitment to patient safety and entrusting The Joint Commission to assist you."

"We are honored to once again receive Joint Commission accreditation," said Susan West Levine, CEO of Lowell CHC. "The Joint Commission is the premier health care quality improvement and accrediting body in the nation. I commend our hard-working staff from across the organization and our board members, who continue to work together to improve care for the patients in our community."

The Joint Commission's ambulatory health care standards are developed in consultation with health care experts and providers, measurement experts, and patients. The standards are informed by scientific literature and expert consensus to help organizations measure, assess and improve performance.



តមកពីទំព័រទី ០១

## ឡូវែលបោះឆ្នោតផ្តាច់ព្រ័តថ្ងៃទី០៦...

"នៅឡូវែលមានសន្លឹកឆ្នោតស( មិនបានគូសឱ្យបេក្ខជនណាម្នាក់)រហូតដល់២ពាន់សន្លឹក។ អ្នកបច្ចេកទេសនៅឡូវែល បានបញ្ចេញយោបល់ថា "នៅបន្ទប់បោះឆ្នោតថ្ងៃនោះ មានសីតុណ្ហភាពក្តៅ ម៉ាស៊ិនទទួលសន្លឹកឆ្នោត ដែលមានចំណាស់ជាង២០ឆ្នាំមកហើយនោះ អាចនឹងមិនមានដំណើរការប្រក្រតីទេ, ចំណែកការរាប់សន្លឹកឆ្នោតដោយដៃនៅពេលបន្ទាប់មកវិញនិយាយថា"គឺជាឆ្នោតដ៏ច្រើនដែលមិនបានគូសឱ្យបេក្ខជនណាម្នាក់ទេ"។ ក្រុមអ្នកវិភាគនិយាយថា"គឺជាឆ្នោតសង្កាត់លេខ១៨" ដែលអ្នកបោះឆ្នោតបានផ្តោតអារម្មណ៏តែទៅលើការប្រកួត"ស្តេតរ៉ិប"តែមួយមុខមិនរវល់នឹងស្គាល់បេក្ខជនដ៏ច្រើន ដែលឈរឈ្មោះជាសមាជិកសភាដំណាងរាស្ត្រនោះទេ ហេតុមិនស្គាល់នោះហើយបានជាអ្នកបោះឆ្នោត មិនបានបោះឆ្នោតឱ្យនរណាម្នាក់សោះ ។

ថ្ងៃទី១៨កញ្ញា ជាថ្ងៃប្រកាសឈ្មោះរបស់ ឡូរី ត្រាហាន នៅសណ្ឋាគារ"យូម៉ាស់ឡូ" ក្រោមអធិបតីភាពលោកស្រី សុងគ្គាស ភ្ញៀវជាបេក្ខជន នឹងជាសមាជិកគណបក្សប្រជាធិបតេយ្យទាំងអស់ប្រមាណ២០០នាក់ បានមកចូលរួមជួបជុំគ្នាជានាគ្នាឡើងវិញ យ៉ាងរីករាយពីក្រោយការដឹកនាំរបស់ជ័យលាភី ឡូរី ដើម្បីប្រកួតយកឈ្មោះបេក្ខជន



ឡូរី ត្រាហាន ពេលជាប់ឆ្នោត

តមកពីទំព័រទី ០៩

## សាលមហោស្រព"MCC"ទើប....

ទៀត។

លោកស្រី នីគី សុងគ្គាស សមាជិកសភាអាមេរីកាំងប្រចាំរដ្ឋម៉ាសាឈូសិត បានជាអ្នកជួយជ្រោមជ្រែងស្វែងរកថវិការពីសហព័ន្ធ ដើម្បីកសាងគុណប្រយោជន៍ដល់គម្រោងដ៏សំខាន់នេះ ជាមួយនឹងអតីតប្រធាន MCC អ្នកស្រីបណ្ឌិត ខេរ៉ូល ខូវ៉ាន់ តាំងតែពីច្រើនឆ្នាំមកហើយ ទម្រាំធ្វើឱ្យសម្មិទ្ធិដែលគេរង់ចាំដោយទន្ទឹងកើតឡើងបាននាថ្ងៃនេះ។

សាលមហោស្រពដែលជាមជ្ឈមណ្ឌលសិល្បៈនេះ បានកើតជារូបរាងនៅទីក្រុងដែលសប្បូរប្រជាពលរដ្ឋខ្មែរ នឹងជនជាតិអាស៊ីអគ្នេយ៏ ដែលមានប្រវត្តិយូរអង្វែង ខាងសិល្បៈរបាំ ដូរ្យដន្ត្រី នឹងចម្លាក់... ហើយដែលស្នាដៃដែលទើបនឹងកើតឡើងនៅឡូវែលរបៀបនេះ គឺជាសំណាងរបស់អ្នកទាំងនោះ ដែលអានរៀនសូត្រ សម្តែង នឹងផ្សព្វផ្សាយពង្រឹងសិល្បៈខ្លួនឡើងវិញ នៅទីនេះបានជាបាក្រដ។

សាលមហោស្រព"Richard &Nancy Donahue Family Academic Art Center"មានកន្លែងសម្រាប់សម្តែងកម្មវិធីល្ខោនប្រគុំភ្លេងកម្មវិធីរាំរបាំ ឬទស្សនីយភាពរៀបជាកន្លែងអង្គុយទស្សនាសិល្បៈច្រើនរយកៅអី មានទាំងកន្លែងហាត់លេងភ្លេង នឹងមានថ្នាក់សម្រាប់បង្ហាត់បង្រៀនសិស្សទាំងអស់មានទំហុំ៩០០"សកែ្វរហ្វូត"ទៀត ផង។



បុប្ផា ម៉ាលូន និងក្រុមប្រឹក្សាមហាវិទ្យាល័យMCC




ក្រុមហ៊ុន ស៊ែល វ៉ាងន័រ អ៉ីនធ័នាសិនទល (Sherle Wagner International) កំពុងស្វែងរកបុគ្គលិកពេញម៉ោងជួយខាងផ្នែកផលិតទូទៅដែលមានទីតាំងនៅក្រុងហ្វល រីវើ (Fall River) រដ្ឋមាសាឈូសេត។ ការងារមានដូចជាដំណើរការឧបករណ៍ប៉ូលីសឲ្យរលូងដើម្បីធ្វើឲ្យផលិតផល និងចំណែកនៃផលិផលរលូងស្អាតតាមការចង់បាន។ ធ្វើការសំលៀង, ខាត, សំអាត រឺក៏ប៉ូលីសឲ្យរលូងដើម្បីឲ្យស្អាត់បន្ថែមទៀត។ កាន់កន្លែងបញ្ជាម៉ាស៊ីនដើម្បីកែសម្រួលឲ្យដំណើរបានត្រឹមត្រូវ, ចាប់ផ្តើមឲ្យដំណើរការ ឬបញ្ឈប់ម៉ាស៊ីន។ ធ្វើការតម្លើងគ្រឿងមេកានិកតូចៗ ជាមួយឧបករណ៍ប្រើដោយដៃ។

ទំនាក់ទំនងអ៊ីម៉េល jobs@sherlewagner.com

អាស័យដ្ឋាន 1 Lewiston St, Fall River MA

Sherle Wagner International is seeking Full Time General Manufacturing help in our Fall River, MA. location. Operates polishing equipment to obtain desired polish on parts and products. Grind, Sand, Clean or Polish objects for further finishing. Move controls to adjust, start or stop mechanical equipment. General small mechanical assembly with hand tools.

Email: jobs@sherlewagner.com

1 Lewiston St, Fall River MA

# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY

## WITH COST EFFECTIVE NEWSPAPER ADVERTISING

KhmerPost USA




### DISTRIBUTION

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

### PUBLISHING

*Two Issues Every Month*

### READERSHIP

*50,000 Monthly*
*600,000 Annually*

***Khmer Post USA Distribution Locations Include:***

- *Households*
- *Markets*
- *Retail Businesses*
- *Restaurants*
- *Office Buildings*
- *Government Offices*
- *Chamber of Commerce*
- *Buddhist Temples*
- *Laundromats*
- *And Much More*

| 2018 PRINTING DATES | 2018 PRINTING DATES |
|---|---|
| Jan 8 and 22 | July 9 and 23 |
| Feb 5 and 19 | Aug 6 and 20 |
| Mar 5 and 19 | Sept 10 and 24 |
| Apr 9 and 23 | Oct 8 and 22 |
| May 7 and 21 | Nov 5 and 19 |
| Jun 4 and 18 | Dec 3 and 17 |

***Advertising deadlines are 5 business days prior to printing date.***

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 5% Savings | 6 Months (12 Issues) 7.5% Savings | 12 Months (24 Issues) 10% Savings |
|---|---|---|---|---|
| **Full** (10” x 13”) | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10” x 6.5”) | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5” x 6.5”) | 165 | 940 | 1831 | 3,564 |
| **1/8** (5” x 3.25”) | 90 | 513 | 999 | 1,944 |

### CONTACT INFO

**45 Merrimack Street • Suite 218A • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092 • Email: sobenpin@khmerpost.us**
**www.khmerpost.us**

CELEBRATING 10 YEARS

*Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau*